**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ៣០៩.........កប/ប្រ.ក

រាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៧

## ប្រកាស

## ស្តីពី

## លក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសស្រែអំបិល

## រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យម្ហូបអាហារសំរាប់មនុស្ស
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១.-**

និយោជក គ្រប់សហគ្រាស សិប្បកម្ម ស្រែអំបិលទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួនទាំងអស់ លើលក្ខខណ្ឌការងារ ដោយធានាសុវត្ថិភាព និងជីវភាពរស់នៅដ៏សមរម្យ និងមានអនាម័យត្រឹមត្រូវ ។

**ប្រការ ២.- សម្លៀកបំពាក់ការងារ**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្លៀកបំពាក់២សម្រាប់ក្នុង១ឆ្នាំ ។

សម្រាប់ទី១ ត្រូវផ្តល់ឱ្យនៅពេល ១៥ថ្ងៃ ក្រោយពីកម្មករនិយោជិតនោះបានចូលធ្វើការដំបូង។ សម្លៀកបំពាក់ ១សម្រាប់ៗត្រូវមាន ២ផ្នែក យ៉ាងតិច គឺសំពត់ឬខោ ហើយនិងអាវ ដែលមានទំហំស្របនឹងខ្លួនប្រាណ ព្រមទាំងសកម្មភាពការងាររបស់កម្មករនិយោជិត។ និយោជក ត្រូវផ្តល់មធ្យោបាយសម្រាប់ថែទាំសម្លៀកបំពាក់ទាំងនោះ ដូចជាសាប៊ូជាដើម។

បទបញ្ជាផ្ទៃក្នុងអាចកំណត់ពីលក្ខខណ្ឌដែលសំលៀកបំពាក់នេះត្រូវបែងចែក ប្រើប្រាស់ និងថែទាំ។

## ប្រការ ៣.- សម្ភារៈការពារបុគ្គល និងសម្ភារៈការងារ

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្ភារៈការពារបុគ្គលជាចាំបាច់ ដូចជាស្បែកជើង កៅស៊ូកវែង ស្រោមដៃកៅស៊ូ ឬមួកបាមធំជាដើម។ល។ សម្ភារៈការងារ ដូចជាខ្នោស ដងវែក ខ្សែ ចប រនាស់ជាដើម ត្រូវមាន សភាពមាំទាំ មិនបង្កឱ្យមានការលំបាក ឬបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស។

## ប្រការ ៤.- ភេសជ្ជៈអនាម័យ

និយោជកនៃសហគ្រាសស្រែអំបិលត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ដល់កម្មករ និយោជិតរបស់ខ្លួនស្របទៅតាមប្រកាសលេខ០៥៤ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ។

## ប្រការ ៥.- ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម

ការលើកដាក់ទម្ងន់ផ្សេងៗ ជាពិសេសសម្រាប់ស្ត្រីនិងកុមារអាយុក្រោម១៨ឆ្នាំ ត្រូវអនុវត្តឱ្យបានស្របទៅតាមប្រកាសលេខ១២៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម។

## ប្រការ ៦.- ទីលំនៅរស់នៅសម្រាប់កម្មករនិយោជិត និងគ្រួសារ

ក្នុងករណីដែលកម្មករនិយោជិតមកស្នាក់រស់នៅក្នុងការដ្ឋានស្រែអំបិល ទោះដោយមានតែបុគ្គលខ្លួនម្នាក់ឯង ឬជាគ្រួសារ ទាំងមូលក៏ដោយ និយោជកមានកាតព្វកិច្ចរៀបចំឱ្យមានវាសនដ្ឋាន សម្រាប់កម្មករ និយោជិតគ្មានគ្រួសារនៅផ្សេង ហើយកម្មករនិយោជិតដែលមានគ្រួសារស្នាក់នៅតាមគ្រួសារនីមួយៗដោយឡែក។ ការរៀបចំវាសនដ្ឋាននេះត្រូវធ្វើឱ្យស្របនឹងប្រកាសស្តីពីការរៀបចំវាសនដ្ឋានសម្រាប់កម្មករនិយោជិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ប្រការ ៧.- ការងារសម្រាប់ស្ត្រី និងកុមារ

កុមារអាយុក្រោម១៥ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការងារអ្វីទាំងអស់ក្នុងការដ្ឋានស្រែអំបិល ទោះដោយថា ជាការជួយការងារ ឪពុកម្តាយក៏ដោយ។

កុមារអាយុចាប់ពីអាយុ១៥ឆ្នាំឡើងទៅ អាចអនុញ្ញាតឱ្យធ្វើតែការងារដែលមិនប៉ះពាល់ដល់សុខភាព សន្តិសុខ និងសីលធម៌ របស់កុមារទាំងនោះ។

ចំពោះស្ត្រីដែលមានផ្ទៃពោះ ចាប់ពីបីខែឡើងទៅ អាចអនុញ្ញាតឱ្យធ្វើតែការងារស្រាលៗប៉ុណ្ណោះ។

**ប្រការ ៨.-** **សេវាសុខភាព**

និយោជក នៃសហគ្រាស សិប្បកម្មស្រែអំបិល ត្រូវរៀបចំឱ្យមានសេវាសុខភាពសម្រាប់កម្មករនិយោជិតរបស់ខ្លួនស្របនឹង ប្រកាសរួមលេខ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងប្រកាសរួមលេខ ១៣៩ ស.ក.ប.យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌនិងបេសកកម្មសេវាពេទ្យសហគ្រាស ។

**ប្រការ ៩.-**

ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យឬទទួលទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- គ្រប់ក្រសួងពាក់ព័ន្ធ **"ដើម្បីជូនជ្រាប"**
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង
  **"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"**
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា **"ដើម្បីអនុវត្ត"**
- សហព័ន្ធសហជីព **"ដើម្បីជូនជ្រាប"**
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ **"ដើម្បីជួយផ្សព្វផ្សាយ"**
- កាលប្បវត្តិ និងឯកសារ